
PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
- Life Insurance
- Car Insurance
- Refinance Your Debts
- Investments
- Office or Home Appointment.
We also provide translation and interpretation services.
យើងផ្តល់ការបកប្រែភាសា តាមក្រដាស ឬផ្ទាល់មាត់
E-mail: 8666823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034



# ខ្មែរប៉ុស្តិ៍
THE KHMER POST
ISSUE 43 04th - 25th September 2009



ហាងមាសរស្មី
SUNSHINE JEWELRY INC
•Fine Jewelry
•Certified Diamonds & Custom Design

702 Washington Avenue
Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com


## ហ៊ុន សែន ព្រមានទប់ទល់ជាមួយ មូរ សុខហួរ
## ទាំងផ្លូវច្បាប់ និងយោធា





**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល** •••ក្រោយពីតុលាការក្រុងភ្នំពេញសម្រេច ឱ្យ ហ៊ុន សែន ឈ្នះលោកស្រីមូរ សុខហួរ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ក្នុងបណ្តឹង តទៅទំព័រទី ១០

## កុំភ័យខ្លាចការធ្វើជំរឿនស្ថិតិប្រជាជនអាមេរិកឆ្នាំ 2010



**ក្រុងខ្មែរ, ខ្មែរប៉ុស្តិ៍ : សុមនា**

•••ទាំងមន្ត្រីជំរឿន និងមន្ត្រីនៃអង្គការសហគមន៍ខ្មែរUCC បានជួបជុំគ្នាមួយកាលពីពាក់កណ្តាលខែសីហា បំណងប្រាប់ដល់បងប្អូនខ្មែរដែលកំពុងរស់នៅទីក្រុង Long Beach និងតំបន់ជាយក្រុងនានាជុំវិញ សូមកុំឱ្យមានការបារម្ភ និងភ័យខ្លាចពីការសាកសួរព័ត៌មានទាក់ទងទៅនឹងការដើរធ្វើជំរឿនស្រង់ស្ថិតិតាមលំនៅឋានពីពួកមន្ត្រីធ្វើការងារ Census ឱ្យរដ្ឋាភិបាលអាមេរិកនោះ ដោយកុំគិតឃើញទៅរកផ្លូវថា បានធ្វើឱ្យប៉ះពាល់ដល់អសន្តិសុខអាយុជីវិត ឬប៉ះពាល់ក្នុងបញ្ហានយោបាយណាមួយមកលើខ្លួន។

ពួកមន្ត្រីជំរឿនស្ថិតិប្រជាជន Census ឆ្នាំ2010 បានថ្លែងថា ការជំរឿនសាកសួរពីប្រជាជនត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មានទាំងឡាយណាដែលទទួលបាន ។ បើមានករណីរំលោភបំពានណាមួយជុំវិញពីបទបញ្ញត្តិនៃច្បាប់នេះ បុគ្គលជាមន្ត្រីជំរឿនត្រូវជាប់គុក 5ឆ្នាំព្រមទាំងពិន័យជាទឹកប្រាក់ចំនួន25ម៉ឺនដុល្លារអាមេរិកទៀតផង។

យោងតាមច្បាប់ការិយាល័យជំរឿនប្រជាជនមិនអាចចែករំលែកផ្សព្វផ្សាយដោយបញ្ចេញព័ត៌មានរបស់បុគ្គលណាម្នាក់ឱ្យទៅបុគ្គលណាម្នាក់ទៀតបានឡើយ រួមទាំងក្រសួង Welfare និងភ្នាក់ងារអន្តោប្រវេសន៍ តទៅទំព័រទី ០៩

សូមអញ្ជើញលោកអ្នកអានអត្ថបទជាភាសាអង់គ្លេស នៅទំព័រខាងក្នុង ដែលបានដកស្រង់ចេញពីសារព័ត៌មាន The Cambodia Daily នៅប្រទេសកម្ពុជា ៕


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន
កក់សណ្ឋាគារ ឬជួលឡាន
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069
Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...




កឹមភៀន ជាមួយគ្រូ និងសិស្សរួមថ្នាក់

**និស្សិតសាកលវិទ្យាល័យថ្មីថ្មោង** : ខ្មែរប៉ុស្តិ៍មានការកោតស្ញប់ស្ញែងដល់សិស្សសាកលវិទ្យាល័យ CCP កឹមភៀន ដែលជាព្រឹទ្ធាចារ្យវ័យ ៧០ ឆ្នាំ របស់ខ្មែរ លោកស្រេកឃ្លានការសិក្សា ស្ពាយកាតាមត្រឡប់ចូលសាលា ដោយក្តីសង្ឃឹមថា នឹងនាំយកចំណេះថ្មីៗទៀតមកជូនមិត្តអ្នកអាន. ខ្មែរប៉ុស្តិ៍មានមោទនភាពជាទីបំផុតចំពោះនិស្សិតកឹមភៀន ដែលជាអ្នកនិពន្ធមនោសញ្ចេតនា ៕


Mobile-net
We connect you to the world!
Since 1995
ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី
សំរាប់ទូរស័ព្ទទៅកម្ពុជាដោយឥតយកកំរៃ !
6.9¢ កម្ពុជា
1.9¢
5.5¢ ឡាវ
សេវាទូរស័ព្ទអន្តរជាតិ
ដ៏ប្រសើរបំផុត

គ្មានការកំណត់គ្មានយកកំរៃលើការតភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំគ្មានតម្លៃប្រែប្រួល
my011.com
1(800) 818-9000

# គណបក្សសិទ្ធិមនុស្ស

បំរើ-ការពារ-កសាង

## HUMAN RIGHTS PARTY



ដឹកនាំដោយឯកឧត្តម កឹម សុខា

សូមអញ្ជើញលោក.លោកស្រីមើលក្នុងគេហទំព័រ www.HRPCambodia.info ដើម្បីស្តាប់វិទ្យុ និងតាមដានព័ត៌មានទាន់សភាពការណ៍ ទាក់ទងនឹងប្រទេសកម្ពុជា ។ បើអស់លោកចង់ចូលរួម សូមទាក់ទងមក

លោក ញ៉ាយ ចំរើន ទូរស័ព្ទ : 267-226-7861 អ៊ីម៉ែល : chamroeunkh@yahoo.com

---

Join the Beloved St. John Community Development Corporation for



**Unity in the Community**

Saturday, September 19,2009 Health Fair
(Screenings) 11am to 2 pm Food, Games, Performances
12 noon to 5pm Rain Date - September 26,2009

Beloved St. John Evangelistic Church
Rev. Clement M. Lupton, III, Sr. Pastor
4541 N. Broad Street
Philadelphia, PA 19140 (215) 329-5140

HIV CIRCLE OF CARE

Albert Einstein Healthcare Network

Beth Grossman, Chief Assistant District Attorney
Public Nuisance Task Force

Health Partners — In Wellness and Health, Partners for Life.
American Diabetes Association
Philadelphia Zoo
NNCC
Mayor's Office of Community Service
Centers for Medicare and Medicaid
National Kidney Foundation
U.S. Dept. Health & Human Services
Office of Behavioral Health
Nazareth Hospital

---

# NEW ASIA AMERICA TRAVEL, INC.

## Domestic & International Travel Services

| | |
|---|---|
| Serve all major airlines: | បំរើលោកអ្នកដោយក្រុមហ៊ុនអាកាសចរសំខាន់ជាច្រើន |
| Tours-cruises | រៀបចំដំណើរកំសាន្ត "ទូ" តាមនាវាចរ |
| Reentry permits/visa | លិខិតអនុញ្ញាត "រីអិនទ្រី ភើមីត" |
| Passport photos | រូបថតដាក់លិខិតឆ្លងដែន |
| Honeymoon packages – specials | ទេសចរណ៍ស្វាមីភរិយាថ្មីថ្មោងពិសេស |
| Single paper | |
| Special Group Tours | រៀបចំធ្វើដំណើរពិសេសជាមួយក្រុម |
| Walt Disney 4-8 days | ដំណើរទៅ "វ៉ាល់ឌីសណេ" ៤-៨ថ្ងៃ |
| Las Vagas 4-7 days | ដំណើរទៅ "ឡាសវេហ្គាស" ៤-៧ថ្ងៃ |
| California 7-10 days | ដំណើរទៅ "កាលីហ្វ័រនីញ៉ា" ៧-១០ ថ្ងៃ |
| Hawaii 6-14 days | ដំណើរទៅ "ហាវ៉ៃ" ៦-១៤ថ្ងៃ |
| Caribbean –Mexico | ដំណើរទៅ "ខារីប៊ិន-ម៉ិកស៊ិក" |
| Europe 7-21 days | ដំណើរទៅ "យូរ៉ុប" ៧-២១ថ្ងៃ |
| Asia: China, Hong Kong, | ដំណើរទៅអាស៊ី :ចិន,ហុងកុង |
| Singapore, Malaysia, | ដំណើរទៅ សិង្ហបុរី |
| Thailand, Cambodia 10-21 days. | ដំណើរទៅប្រទេសថៃ-កម្ពុជា ១០-២១ថ្ងៃ |
| Money Transfer (Vietnam only) | ផ្ញើការផ្ញើប្រាក់ (វៀតណាមប៉ុណ្ណោះ) |
| Citizenship test | ធ្វើតេស្តសំរាប់ចូលសញ្ជាតិ |
| Pin and Pinless phone cards. | មានកាតទូរស័ព្ទ មានលេខសម្ងាត់ ឬគ្មាន |

Dung Phat Plaza Tel: (215) 468-7876
1110 Washington Ave., #6 Fax: (215) 468-7917
Philadelphia, PA 19147 E-mail: info@naatravel.com
www.newasia-americatravel.com

---



# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300



សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាប" យើងធ្វើចុងពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៨រូប ដែលមានជំនាញគ្រប់គ្រាន់ក្រោយនៅវិជ្ជាធ្វើធ្មេញ ។

**មណ្ឌលធ្មេញឯកទេសខាងការទារលំអរ**

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហ្វៀតែមួយដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួសដែលផលិតឡើងតាមគុណភាពដែលលោកអ្នកចង់បានទាំងអស់ សុទ្ធតែដំណើរការដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

**ទន្តសាស្ត្រទូទៅ**

- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ចិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- **-សំអាតធ្មេញឱ្យសស្អាត:** ដោយធ្វើដោយឡេស៊ែរមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

ថ្ងៃ ច័ន្ទ : 10am-6pm
ថ្ងៃ អង្គារ : 10am-6pm
ថ្ងៃ ពុធ : 10am-7pm.
ថ្ងៃ ព្រហស្បតិ៍ : 10am-6pm
ថ្ងៃ សុក្រ : 10am-6pm.
ថ្ងៃ សៅរ៍ : 10am-7pm

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**ចុះថ្លៃ 10% ដល់អ្នកគ្មានបណ្ណសុខភាព**



**អាចធ្វើផែនការណ៍បង់ប្រាក់ប្រចាំខែ**

ទស្សនៈនយោបាយ:

# វិបត្តិនយោបាយថៃទាក់ទងនឹងប្រទេសកម្ពុជា



ដោយ : ម៉ម យឺន

●●●ប្រព័ន្ធឃោសនាការផ្សព្វផ្សាយព័ត៌មាន ដូចជាស្ថានីយ៍វិទ្យុទូរទស្សន៍ វិទ្យុផ្សាយសម្លេង សារព័ត៌មានជាដើម ដែលបានធ្វើឱ្យអ្នកស្តាប់ទូទៅមើលឃើញថា ថៃបានប្រកាន់នូវគោលការណ៍ឯករាជ្យ និងតម្លាភាពគ្រាន់មើលជាងប្រទេសជិតខាងខ្លះ ។

ភាពជាឯករាជ្យនៅក្នុងទូរទស្សន៍ ASTV NEWS 1 បានផ្សាយចេញនៅក្នុងសប្តាហ៍កន្លងមកនេះ ធ្វើឱ្យជនជាតិខ្មែរ ដែលរស់នៅឯនាយសមុទ្រ មានការចាប់អារម្មណ៍យ៉ាងខ្លាំង :

**១. ការបង្កើតធម្មនុញ្ញ បក្ស ប្រទេសអង្គការអាស៊ាន :**

បច្ចុប្បន្នកាលនេះ ប្រទេសថៃ កំពុងមានមុខនាទីធ្វើជាប្រទេសនៃអង្គការអាស៊ាន ទទួលបន្ទុកជាមេដឹកនាំការប្រជុំទាំងអស់នៅក្នុងប្រទេសថៃ ដូច្នេះកិច្ចការ និងបញ្ហាសំខាន់ៗ ជាច្រើនត្រូវបានលើកឡើងដើម្បីជំនុំពិភាក្សាប្តូរមតិយោបល់គ្នា ដូចជារឿងធម្មនុញ្ញនេះជាដើម ។

លោករដ្ឋមន្ត្រីកិច្ចការបរទេសថៃ ភិសិត ភិរុំ បានថ្លែងថា ធម្មនុញ្ញរបស់អង្គការប្រទេសអាស៊ាន បានបង្កើតឡើងនេះ នឹងផ្តល់ជាប្រយោជន៍ល្អណាស់ដល់ប្រទេសនីមួយៗ ជាសមាជិកមានការងាយស្រួលក្នុងការពង្រឹងចំណងមិត្តភាព ការពង្រឹងសេដ្ឋកិច្ច និងការចែករំលែកការងារដល់បណ្តាប្រជាពលរដ្ឋ ដែលខ្វះការងារធ្វើ ។

លោករដ្ឋមន្ត្រី បន្តថា ធម្មនុញ្ញបានថ្លែងពីវិស័យទេសចរណ៍រវាងប្រទេសមួយទៅប្រទេសមួយ អាចប្រព្រឹត្តទៅបានដោយមិនបាច់មានលិខិតឆ្លងដែន គ្រាន់តែមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ អាចធ្វើដំណើរឆ្លងដែនបានដោយសេរី ។

ការប្រើប្រាស់មូលធនប័ណ្ណ (លុយ) នឹងអាចសម្រួលគ្នា តម្រូវឱ្យមានលុយចាយប្រភេទតែមួយដូចគ្នានៅក្នុងប្រទេសសហគមន៍ផ្សាររួមអឺរ៉ុប ដែលគេបានបង្កើតរួចហើយ ប៉ុន្តែមូលធនប័ណ្ណ (លុយ) នោះពុំទាន់បានកំណត់យកច្បាស់លាស់នៅឡើយទេ ។

ក្នុងវិស័យសង្គមកិច្ច ប្រទេសនីមួយៗ ត្រូវខិតខំពង្រីក និងពង្រឹងសេដ្ឋកិច្ចរបស់ខ្លួនឱ្យបានរឹងមាំនៅក្នុងគ្រប់ស្ថាប័នរបស់រដ្ឋ និងឯកជន រួចហើយមានការជញ្ជូននាំចេញទៅលក់នូវគ្រប់ផលិតផលដែលបង្កបង្កើតបាន មិនឱ្យប្រទេសនីមួយៗ មានការលំបាកក្នុងការរកទីផ្សារអន្តរជាតិនោះទេ ។

ក្នុងវិស័យសង្គមកិច្ចនៅក្នុងប្រទេសខ្លះសំបូរការងារធ្វើ ប៉ុន្តែខ្វះអ្នកធ្វើការ ដូច្នេះ ប្រទេសណាមានបញ្ហាការងារ អាចឱ្យទៅប្រកបការងារនៅក្នុងប្រទេសមួយទៀត បានដោយងាយស្រួលតាមច្បាប់ ។

ក្នុងវិស័យបូរណភាពទឹកដី ប្រទេសនីមួយៗ ត្រូវតែគោរពទៅតាមច្បាប់អន្តរជាតិឱ្យបានត្រឹមត្រូវ ជៀសវាងការរំលោភឈ្លានពានគ្នា ទៅតាមគ្រប់រូបភាពដែលបណ្តាលឱ្យប្រទេសខ្លះកើតវិបត្តិព្រំដែន ។ល។

មានមាត្រាច្បាប់ធម្មនុញ្ញនេះជាច្រើន ដែលលោករដ្ឋមន្ត្រី ភិសិត ភិរុំ បានថ្លែងផ្សាយថា ប្រទេសថៃ ក្នុងឋានៈជាប្រធាន និងជាម្ចាស់ផ្ទះ បានខិតខំប្រឹងប្រែងដឹកនាំរៀបចំក្នុងអង្គបក្សអាស៊ាននេះ ឱ្យមានដំណើរការទៅមុខល្អប្រសើរបំផុត ដើម្បីបំរើផលប្រយោជន៍ប្រទេសជាសមាជិកឱ្យបានល្អប្រសើរ និងដោយយុត្តិធម៌ ។

**២. ការយល់ឃើញពីប្រព័ន្ធដឹកនាំនយោបាយនៅកម្ពុជាសព្វថ្ងៃ :**

អង្គការផ្សព្វផ្សាយព័ត៌មានរបស់ប្រទេសថៃ បានផ្សាយព័ត៌មានពាក់ព័ន្ធជាមួយនឹងការដឹកនាំនយោបាយខ្មែរយ៉ាងវែង ដែលមានជាអាទិ៍ទៅលើសកម្មភាពអនុវត្តន៍គោលការណ៍នយោបាយរបស់សម្តេចអគ្គ-មហាសេនាបតីតេជោ ហ៊ុន សែន អំពីការបែកបាក់សម្បទានដីធ្លី, ការប្រគល់សិទ្ធិអំណាចទៅឱ្យនាយទុនធំៗ ឧកញ៉ាធំៗ មន្ត្រីធំៗ ចូលធ្វើវិនិយោគមុខរបរគ្រប់វិស័យក្នុងកម្ពុជា, ការប្រើអំណាចគ្រប់គ្រងប្រទេសទៅលើជនជាតិខ្មែរ ប្រៀបប្រដូចទៅនឹងការរស់នៅរបស់ជនជាតិអន្តោប្រវេសន៍ផ្សេងៗទៀត ជាពិសេសការប្រព្រឹត្ត និងទង្វើក្នុងអំពើទុច្ចរិត ពុករលួយ រំលោភបំពានលើសិទ្ធិសេរីភាពគ្រប់បែបយ៉ាងក្នុងការប្រើប្រព័ន្ធតុលាការដោយអយុត្តិធម៌ជាដើម ។

ការកត់សំគាល់អំពីទង្វើ និងការប្រព្រឹត្តរបស់រដ្ឋាភិបាលថៃ ទៅលើរដ្ឋាភិបាលកម្ពុជា បានចាត់ទុកដោយការប្រើពាក្យពុំសមរម្យថា រដ្ឋាភិបាលកម្ពុជាជារដ្ឋាភិបាលចោរ ឬជាចោរធិប្បតេយ្យ ដោយគេសំអាងទៅលើការយកព័ត៌មានដោយផ្ទាល់ និងយោងតាមព័ត៌មានផ្សាយចេញពីប្រភពព័ត៌មានអន្តរជាតិផ្សេងៗទៀត ។

អង្គការព័ត៌មានថៃ បាននិយាយប្រៀបប្រដូចប្រទេសកម្ពុជា ទៅនឹងប្រទេសថៃ កាលពីសម័យគ្រប់គ្រងដឹកនាំដោយលោកថាក់ស៊ិន ធ្វើជានាយករដ្ឋមន្ត្រីក្នុងអំឡុងមុនឆ្នាំ ២០០៧ ដូច្នោះដែរ ដែលបានធ្វើឱ្យប្រជាពលរដ្ឋថៃ ស្នេហាជាតិមានការពុំពេញចិត្តនាំគ្នាតវ៉ា ទាមទារឱ្យចុះចេញពីអំណាច ដោយមានកងទ័ពជាតិថៃ ជាអ្នកធ្វើរដ្ឋប្រហារផ្តួលរំលំពីអំណាចនាថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ រហូតមកដល់សព្វថ្ងៃ ។

នៅក្នុងការអនុវត្តន៍គោលនយោបាយរបស់មេដឹកនាំខ្មែរនេះ ប្រទេសថៃ ចង់ឃើញឱ្យមានការប្រកាន់យកគោលការណ៍លទ្ធិប្រជាធិបតេយ្យ ពិតប្រាកដ ដែលមេដឹកនាំទាំងអស់បានចុះហត្ថលេខាក្នុងកិច្ចសន្យារបស់អង្គការសហប្រជាជាតិ ស្តីពីលទ្ធិប្រជាធិបតេយ្យនេះ ដោយសណ្តានចិត្តស្មោះត្រង់ និងគតិយុត្តិធម៌ ។

ការប្រព្រឹត្ត និងទង្វើដូចគ្នារបស់ប្រទេសកម្ពុជា និងប្រទេសម៉ាយ៉ាម៉ា (ភូម៉ា) សព្វថ្ងៃនេះ ឃើញថាផ្ទុយគ្នាទាំងស្រុងពីច្បាប់អន្តរជាតិ ហើយបង្កើតឱ្យមានអំពើ និងរបបអនាធិបតេយ្យ នៅក្នុងគ្រប់ស្ថាប័នជាតិ ដែលកើតចេញមកពីអំពើទុច្ចរិត ពុករលួយ និងអយុត្តិធម៌របស់មន្ត្រីគ្រប់ជាន់ថ្នាក់មួយចំនួន ។

**៣. រដ្ឋាភិបាលថៃ ប្រឈមមុខនឹងបក្សអាវក្រហមឆ្នោ**

ក្រុមបក្សប្រឆាំងអាវក្រហម ដែលគេស្គាល់ថា ជាបក្សគាំទ្រ និងស្វាមីភក្តិបំផុតចំពោះលោកថាក់ស៊ិន បានប្រជុំធ្វើញត្តិសុំព្រះមហាក្សត្រ ឱ្យលើកលែងទោសដល់ថាក់ស៊ិន ដែលតុលាការជាន់ខ្ពស់ថៃ បានកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ២ឆ្នាំ កាលពីឆ្នាំ ២០០៧ កន្លងមក ហើយបានរត់ចេញពីប្រទេសថៃ ទៅរស់ក្រៅប្រទេសរហូតមក ។

ក្រុមអាវក្រហម ដែលមានមេនាំធំ ជាសមាជិកតំណាងរាស្ត្រ បានប្រមូលញត្តិបានចំនួន ៦លានច្បាប់ នាំគ្នាប្រជុំនៅក្នុងទីធ្លាស្នាមហ្លួង ប្រមាណ២សែននាក់ សែងដង្ហែញត្តិទៅថ្វាយព្រះមហាក្សត្រ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ដោយមានសំលៀក-បំពាក់កំណាត់សំពត់វេចញត្តិ និងស្នែងសែងញត្តិ សុទ្ធតែពណ៌ក្រហមឆ្អៅ ដើរដង្ហែរទៅកាន់សំណាក់ព្រះ-អគ្គលេខាធិការព្រះរាជវាំង ដើម្បីថ្វាយសូមការលើកលែងទោសតាមព្រះហឫទ័យអធ្យាស្រ័យឱ្យលោកថាក់ស៊ិន បានវិលត្រឡប់មកប្រទេសថៃវិញ បានដឹកនាំប្រទេសជាតិបន្តទៅទៀត ។

តាមការផ្សាយព័ត៌មាន បានឱ្យដឹងថា មានមតិយល់ឃើញជាច្រើន បានយល់ថា ការធ្វើញត្តិសុំអភ័យទោសនេះ លុះត្រាធ្វើដោយសាមីខ្លួនផ្ទាល់ និងក្រុមគ្រួសារ ក្រោយពីបានចូលខ្លួនមកទទួលទោសសិនបើមិនដូច្នេះទេ គឺជាការខុសច្បាប់ ម្យ៉ាងទៀតញត្តិនេះអាចបញ្ជូនទៅថ្វាយស្តេចបាន លុះត្រាតែធ្វើទៅតាមរយៈរដ្ឋាភិបាល ទើបស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ។

ក្រោយពីញត្តិបានទៅដល់តំណាក់អគ្គលេខា ហើយតំណាងអគ្គលេខាធិការបានចេញមកទទួលយក ហើយបញ្ជូនត្រឡប់មករដ្ឋាភិបាលវិញ ដើម្បីធ្វើការត្រួតពិនិត្យ ពិចារណា រួចហើយនឹងដាក់ថ្វាយព្រះមហាក្សត្រ ។ **តទៅទំព័រទី ១៣**

From :Philadelphia



សួស្តីឆ្នាំថ្មី
ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service




State and Emission Inspection General Repairs and Maintenance

MON-SAT. 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ៉ាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកំរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

## (តមកពីទំព័រទី ០៣) ពេលវេលាមកដល់ដើម្បីឲ្យខ្លា....

បាកនៃជម្លោះគឺប៉ះពាល់ដល់អាស៊ានទាំងមូល ។ ហេតុផលទីពីរនោះអាស៊ានអាចចាត់ទុកជាឪពុកម្តាយរបស់ប្រទេសទាំង10 ។ ដូច្នេះនៅពេលដែលកូនឈ្លោះគ្នា ឪពុកម្តាយមានកាតព្វកិច្ចជួយដោះស្រាយដោយឈរលើគោលការណ៍មិនលំអៀង និងយុត្តិធម៌ ។ ហេតុផលទីបីដែលសំខាន់នោះដែរ គឺគោលការណ៍យុត្តិធម៌សង្គម និងការគោរពច្បាប់ ។ អាស៊ានត្រូវតែមានអំណាចដើម្បីស្វែងរកយុត្តិធម៌ដល់សមាជិកទាំងអស់ដើម្បីធានាថា អង្គការនេះអាចពឹងពាក់បានហើយ ជាអង្គការមួយដែលបំរើសមាជិក និងលើកស្ទួយយុត្តិធម៌ ព្រមទាំងការអនុវត្តច្បាប់ ។

បើសិនជាអាស៊ានមិនឆក់យកឱកាសនេះ ដើម្បីបង្ហាញអំពីសមត្ថភាពរបស់ខ្លួនទេនោះ អាស៊ាននឹងធ្វើឱ្យសមាជិកក៏ដូចជា សហគមន៍អន្តរជាតិពិបាកនឹងជឿទុកចិត្ត ។ អាស៊ាននឹងមិនមែនជាម្លប់ដ៏ត្រជាក់សម្រាប់សមាជិកហើយ ក៏មិនមែនជាសមាគមមួយដែលបម្រើផលប្រយោជន៍រួមឡើយ ៕



បុត្រព្រះបាទនរោត្តម
ព្រះអង្គចន្ទលេខា ហៅ តូ





ព្រះសង្ឃកោរសក់កំប៉ោយ និងស្រោចទឹកមន្ត

...." ទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ មានច្រើនណាស់ ដែលបុព្វបុរសបានបន្សល់ទុកសម្រាប់យកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ប៉ុន្តែក្នុងចំណោមទំនៀមទម្លាប់ទាំងនោះ ខ្លះក៏នៅគង់វង្ស និងខ្លះទៀតក៏ចាប់ផ្តើមរលាយសាបសូន្យជាបណ្តើរៗហើយ ។ ក្មេងប្រុសស្រីកាលណាជិតដល់វ័យរៀបការគេតែងរៀបចំពិធីកោរជុកមិនដែលខកខាននោះទេ ប៉ុន្តែសព្វថ្ងៃនេះ ទំនៀមទម្លាប់កោរជុកគេបានបោះបង់ចោលជាបណ្តើរស្ទើរអស់ គឺនៅសេសសល់តែស្រុកសូទ្រនិគមមួយប៉ុណ្ណោះ "...។

# ពិធីកោរជុកនៅមានសេសសល់ លើទឹកដីស្រុកសូទ្រនិគម

**សៀមរាប, ខ្មែរប៉ុស្តិ៍ : គឹម សារឿន**

●●●"ពិធីកោរជុក" អ្នកស្រុកខ្លះនិយម ហៅថា "កោរសក់ ឬកោរកំប៉ោយ" ដែលទុកសក់ កំប៉ោយ1ដុំ 2ដុំ ឬ3ដុំនៅលើក្បាល គឺក្មេងស្រី ឬប្រុសអាយុចាប់ពី3ឆ្នាំដល់13ឆ្នាំ ដែលគេហៅថា "ពិធីរៀបពេញវ័យ" ត្រៀមលក្ខណៈរៀបការ ។ ការកោរជុកនេះភាគច្រើនគឺធ្វើឡើងលាយឡំ គ្នាចាប់ពីក្មេង5ទៅ 10នាក់ក្នុងភូមិ មិនប្រកាន់ភេទនោះទេ ។

លោក ក្លែប តុង ជាអ្នកស្រុកសូទ្រនិគម បានឱ្យដឹងថា ពិធីនេះមានតាំងពីសម័យបុរាណ ដែលដូនតានិយមធ្វើឱ្យកូនចៅក្នុងភូមិ អំឡុងខែមាឃ ផល្គុន និងពិសាខ រយៈពេល 3ថ្ងៃ គឺមានការចូលរួមពីសំណាក់អ្នកភូមិច្រើនខ្លាំងណាស់ ។ ពេលប្រារព្ធពិធីនេះ គឺចាស់ៗហៅក្មេងៗមកកោរសក់សែនព្រេនចំពោះព្រះវិស្ណុ ធ្វើនំនែក រៀបចំបាយសីសែនក្រុងពាលី និមន្តព្រះសង្ឃសូត្រធម៌ជាដើម ។

លោក ក្លែប តុង បន្តថា កិច្ចបន្តទៅគេឱ្យ ក្មេងៗដេកលើអង្កររាប ដែលមានអាចារ្យជាអ្នក រៀបចំពិធីបង្វិលពពិល ហៅព្រលឹង សូត្រធម៌ក្នុងសម្លេងយឺតៗ ដែលមានខ្លឹមសារថា "មកវ៉ើយព្រលឹងសក់ មើលកុក មើលទុង មើលជ្រុងទន្លេ កុំទៅតាមគេមកផ្ទះយើងវិញ ។ នៅផ្ទះយើងវិញធំស្រណុំស្រណុក ស៊ីចេក អំបុក ស៊ីត្រាវដំឡូង ស៊ីចេកដេកនៅ ស៊ីអំពៅ ដើរលេង គេហៅកុំដោយរមិលមើលក្រោយ រក្សារូប រក្សាអង្គ" ។

ចំណែកលោកបណ្ឌិត អាំង ជូលាន អ្នក ជំនាញផ្នែកនរវិទ្យា បានឱ្យដឹងថា ការរាវអង្ករ រាបនេះគេដាក់នៅក្នុងអង្ករឱ្យក្មេងរាវ បើប៉ះរបស់ល្អ ឬអាក្រក់គេប្រាប់ឱ្យសាមីខ្លួនដឹងជាមុន ដូចជាការចាក់គម្ពីរដែរ ។ នៅថ្ងៃនោះគេឱ្យក្មេង អង្គុយលើកញ្ចើស្រូវបែរមុខទៅព្រះអាទិត្យ ដែលគេធ្វើធ្មេញរួចហើយ ទើបគេនាំក្មេងដើរប្រទក្សិណ3ជុំ រួចព្រះសង្ឃក៏ធ្វើពិធីកោរសក់ជានិមិត្តរូប ហើយស្រោចទឹកលើក្បាលក្មេងឱ្យពរជ័យ ។

លោកបណ្ឌិត អាំង ជូលាន បន្តថា តាមលោកដឹងក្នុងពិធីនោះគេមានរៀបចំបាយសី បាយព្រលឹង ស្រូវកញ្ចើ គ្រឿងអង្កររាបពពិល ប្រដាប់ហៅព្រលឹង ប្រដាប់កោរសក់ ព្រះខ័ន គ្រឿងតុបតែងខ្លួន និងជមផ្សេងៗ ។ ពិធីកោរជប់នេះកាលពីសម័យមុនព្រះមហាក្សត្រ ក៏មានរៀបចំឱ្យបុត្ររបស់ទ្រង់ជាហូរហែរមកដែរ គឺទើបតែស្ងប់ស្ងាត់សម័យយើងនេះទេ ។

លោកបណ្ឌិត អាំង ជូលាន បន្តថា បុត្រព្រះបាទនរោត្តម ព្រះអង្គម្ចាស់ចន្ទលេខា ហៅម្ចាស់តូ ត្រូវបានគេរៀបចំពិធីកោរជុបយ៉ាងអធិកអធមនៅវាំង ក្រុងភ្នំពេញរយៈពេល7យប់7ថ្ងៃ ដែលពិធីនេះត្រូវបានបារាំង ធ្វើការកត់ត្រា និងផ្សព្វផ្សាយទៀតផង។ ប៉ុន្តែសព្វថ្ងៃនេះពិធីកោរជុកហាក់ដូចជាត្រូវគេបោះបង់ចោលលែងនិយមតែម្តង គឺនៅសល់តែខេត្តសៀមរាប ក្នុងស្រុកសូទ្រនិគមតែប៉ុណ្ណោះ ។

នៅក្នុងប្រទេសកម្ពុជាពិធីកោរជុក គឺមាននៅសេសសល់តិចតួចខ្លាំងណាស់ ប៉ុន្តែនៅខេត្ត សុរិន្ទ ស៊ីសាកេត បូរីរម្យ វ៉ាក់យ៉ង... ខ្មែរលើនៅស្រុកសៀមបច្ចុប្បន្ននៅតែបន្តប្រកាន់ទំនៀមទម្លាប់កោរជុកនេះដដែល ។ ពួកគេអះអាងថា ប្រពៃណីនេះកើតតាំងពីមុនសម័យអង្គរម្ល៉េះ ពីព្រោះតាមរយៈចម្លាក់រឿងរាមកេរ្តិ៍ខ្មែរក្នុងព្រះវិហារវត្តបូព៌ ខេត្តសៀមរាប ក្នុងឈុតមួយតួអង្គពាលីស្តេចស្វានៅនគរ ខាស់ខិនបុរី មានរៀបចំធ្វើពិធីកោរជុកឱ្យកូនប្រុសឈ្មោះ អង្គយ៉ាងអធិកអធមផងដែរ ៕



លោកអាចារ្យធ្វើធ្មេញក្នុងពិធីកោរជុក





រោងបុណ្យដ៏អធិករធម

អត្ថបទមនោសញ្ចេតនា

# ក្តីស្នេហ៍គ្មានទីបញ្ចប់...!



**ដោយ : គីម ភឿន** ***(តពីលេខមុន)***

●●●ម្តងនេះ វិរៈ តឹងទ្រូងថ្អឹះទៀតហើយ ! តើត្រូវដោះស្រាយយ៉ាងណា ធ្វើយ៉ាងម៉េចលោកណៃខុន នឹងស្តាប់តាមយោបល់ខ្លួនលើកទី២នេះ ។ វិរៈ ក៏ក្រោករឹងពីគ្រែ ស្ទុះទៅស្បៀកពាក់ ហើយតម្រង់ទៅវិទ្យាល័យតាំងគោក ជាមួយនាយសូភឿ របស់ខ្លួន ។

មនុស្សម្នាកំពុងតែចោមរោមមើលខ្មែរក្រហមដឹកសត់រូបនេះ ដែលបន្តិចទៀតគេនឹងវះអារសាច់ទាំងរស់ ដើម្បីបន្ទរទូវកំហឹងរបស់គេ ។

ពេលចូលទៅក្នុងបរិវេណវិទ្យាល័យភ្លាម វិរៈ ឃើញរថយន្តហ្ស៊ីពចម្លែកពីរគ្រឿងកំពុងចតនៅទីនោះ ។ ដើរទៅជិត វិរៈ បានសង្កេតឃើញមាននាយទាហានមួយចំនួន និងកូនទាហានចម្លែកជាង ១០នាក់ ។ ស្រាប់តែមាននាយកទាហានម្នាក់ទះស្មា វិរៈ ដោយបន្លឺថា : "ប្អូន វិរៈ មកចូលខ្លួនលីដែកលក់ជីវិតពីថ្ងៃណាមកដែរ ? "

នេះជារឿងចំឡែកចំពោះលោកអនុសេនីយ៍ឯក វិរៈ ព្រោះតាំងពីមកស្រុកតាំងគោកនេះ គ្មានអ្នកណាម្នាក់ហ៊ានទះស្មាកម្លោះសោះទេ ។ ការនេះបញ្ជាក់ថា ប្រហែលមានមិត្តជិតស្និទ្ធណាម្នាក់កំពុងមកលេងសើចពីក្រោយខ្នង ។ កម្លោះចាប់ដៃនោះជាប់ ហើយបែរទៅមើលថា តើអ្នកណាមួយទៅ ? ស្រាប់តែស្រឡាំងកាំងដោយភ្ញាក់ផ្អើលមិនដែលនឹកស្មានថា មានព្រឹទ្ធាចារ្យមានបុណ្យធំមកលេងកំប្លែងជាមួយខ្លួនសោះ :

-ឱព្រះតេជគុណ វរៈសេនីយ៍ឯក ! មានខ្យល់បក់ពីណា នាំព្រះតេជគុណមកដល់ទីចុងកាត់មាត់ញកនេះ ?

- មើល ! ហៅម្តងទៀតមើលអាប្អូន ! វរៈសេនីយ៍ឯក ស្អី ? ក្រែងក្នុងពេលយើងជួបគ្នា ក្នុងរាត្រីសមោសរមួយធ្វើនៅផ្សារដេប៉ូ សម្រាប់ឆ្នាំខួបទី៥ នៃសារព័ត៌មានទុក្ខកម្ពុជាក្រោម យើងបានសន្យាគ្នាថា យើងនឹងហៅគ្នាយ៉ាងម៉េច ?

វិរៈ ភ្ញាក់ខ្លួនដូចគេកន្ត្រាក់ : ជាង២ឆ្នាំទៅហើយ... កាលនោះគាត់ពាក់ស័ក្តិ ៤ ឈ្មោះគាត់ហៅថា " លោកស័ក្តិ ៤ កំប៉ុងទឹកត្នោតជូ " ។ ព្រោះគាត់ប្រើឱ្យកូនទាហានម្នាក់ដែលជិតស្និទ្ធ ហើយដៃត្រង់បាញ់មិនចេះខុសនោះ ឱ្យបាញ់កំប៉ុងទឹកត្នោតជូដាក់លើក្បាលគាត់ ។ កូនទាហានមិនព្រមបាញ់ គាត់ក៏បញ្ជាឱ្យកូនទាហាននោះ យកកំប៉ុងទឹកត្នោតជូ ដាក់លើក្បាលខ្លួនឯង គាត់នឹងបាញ់វិញម្តង ។ កូនទាហានខ្លាចគាត់ស្រវឹងទឹកត្នោតជូ បាញ់មិនត្រូវកំប៉ុង បែរជាត្រូវក្បាលខ្លួនឯងវិញ ខ្លួននឹងស្លាប់ចោលប្រពន្ធកូន ។ គេក៏ប្តូរយោបល់ :

- អញ្ជើងខ្ញុំព្រមបាញ់ហើយព្រះតេជគុណ ! ព្រះតេជគុណដាក់កំប៉ុងលើក្បាលទៅ ខ្ញុំតម្រង់បាញ់ដោយកាំភ្លើងខ្លីរបស់ព្រះតេជគុណ ! ។ លោកស័ក្តិ៤ ឈ្លោត ប៊ុត ឱ្យកូនទាហានបាញ់លេងយ៉ាងសប្បាយ ! កូនទាហានតម្រង់កំប៉ុងដោយដៃញ័រៗ :

- ប៉ុង ! កំប៉ុងខ្ទាតចេញពីក្បាលគាត់ បែកខ្ចាយអស់ទឹកត្នោតជូ ! ស្រាប់តែលោកស័ក្តិ៤ បះជើងដួលប្រាវដែរ ! ។ លទ្ធផល គឺកូនទាហានរបស់គាត់បានបាញ់ល្មៀងបន្តិច សើយពីក្រោមកំប៉ុង ជូតស្បែកក្បាលគាត់ ធ្វើឱ្យដាច់សរសៃសន្លប់បាត់ស្មារតី ។ ពេលចេញពីពេទ្យវិញ សរសៃទាញ ធ្វើឱ្យគាត់ជើងខ្លីម្ខាង ហើយធ្វើឱ្យគាត់មានដំណើរប៉ាំងពៀចៗរហូតមក ។ ឃើញ វិរៈ មិនឆ្លើយ លោកស័ក្តិ៥

ឈ្លោត ប៊ុត សំឡុតម្តងទៀត :

- ម៉េចអាប្អូន ឯកភ្លេចពាក្យសន្យាអស់ហើយឬ? យប់នោះឯងសូត្រកំណាព្យ ធ្វើឱ្យយើងសប្បាយចិត្ត...

- ធ្វើម៉េចឱ្យប្អូនបំភ្លេចបាន លោកបង ! លោកបងមានបុណ្យធំ មកស្រឡាញ់រាប់អានខ្ញុំជានិស្សិតក្រ ហើយជាអ្នកនិពន្ធគ្មានអនាគត ។ បងបានធ្វើអីយប់នោះ ខ្ញុំនោះចាំទាំងអស់ ដូចទើបពីម្សិលមិញ បងចង់ឱ្យប្អូនរំលឹកឡើងវិញទេ?

- អើ ! ឯងនិយាយត្រូវ ! រំលឹកមើល !

- កាលនោះជាងពី២ឆ្នាំកន្លងមកហើយ សារព័ត៌មានទុក្ខកម្ពុជាក្រោម ធ្វើបុណ្យរំលឹកខួបឆ្នាំទី៥ របស់ខ្លួននៅហាងមួយ នៅផ្សារដេប៉ូ ។ គេបានអញ្ជើញលោកបងមកអង្គុយរួមតុជាមួយខ្ញុំ ដោយគេប្រាប់ខ្ញុំថា " លោកវរៈសេនីយ៍ត្រី ចង់ជួបខ្ញុំ សុំឱ្យខ្ញុំកំដរលោកវរៈសេនីយ៍ត្រីផង " ។ ឃើញទឹកមុខខ្ញុំងឿងឆ្ងល់ បងនិយាយកាត់ភ្លាម: " ខ្ញុំបានតាមដានរឿងដែលប្អូនសរសេរចុះក្នុងសារព័ត៌មានទុក្ខកម្ពុជាក្រោម មានឈ្មោះថា "ខ្សាច់ ធូលី តាមផ្លូវជីវិត" ។ អានរឿងមិនចេះចប់សោះ ព្រោះប្អូនឯងមិនចង់បញ្ចប់ ឬក៏រឿងនោះវានៅមានដំណើរដើមទងយ៉ាងផ្អែមល្ហែមផង ជូចត់ផង ខ្ញុំចង់ដឹងទីបញ្ចប់ អ្នកតួទាំងពីរនោះនឹងទៅជាយ៉ាងណា ? ***តទៅលេខក្រោយ***

# ស្រឡាញ់ផ្តាច់ការ ជាសញ្ញាស្អប់ប្រជាធិបតេយ្យ



***ដោយ : ម៉ម យឺន***

នៅពេលមានរបបផ្តាច់ការ    ក្នុងប្រទេសណាយ៉ាងខ្លាំងក្លា
ជាតិនោះត្រូវជួបតែបញ្ហា    ទុក្ខព្រោះសោកាគ្មានស្រាកស្រាន្ត ។
ជនចង់ប្រើរបបផ្តាច់ការ    ព្រោះមានចេតនាធ្វើបំពាន
មិនគោរពសោះច្បាប់ធរមាន    នឹងជនណាហ៊ានធ្វើប្រឆាំង ។
ជនណាហ៊ានធ្វើពាក្យរបប    ផ្តាច់ការចោទតបមេនាំខ្លាំង
ខាងឯផ្តាច់ការដោយចិត្តតាំង    ប្រាប់អ្នកប្រឆាំងប្រយ័ត្នខ្លួន ។
សេចក្តីព្រមាននៃជននោះ    ជាជនយល់ខុសពីច្បាប់ក្បួន
អ្នកប្រាជ្ញបណ្ឌិតចិត្តសមសួន    លោកតែងថៃធ្ងួនប្រៀនប្រដៅ ។
គតិបណ្ឌិតពិតមានន័យ    នាំជនប្រុសស្រីដើរផ្លូវត្រូវ
បើចង់ធ្វើមេនាំកូនចៅ    ដើរត្រង់ត្រាច់ផ្លូវទៅស្វែងក្តីសុខ ។
ក្តីយុត្តិធម៌ ចរិយធម៌    ជាធម៌បវរជាប្រមុខ
រួមសច្ចធម៌ត្រូវចាំទុក    ទើបជួយជាតិស្រុកចាកផុតភ័យ ។
ផ្តាច់ការជាតួពាក្យមួយទៀត    ជាពាក្យល្អស្អាតយ៉ាងប្រពៃ
ជារបបប្រជាធិបតេយ្យ    របបមានន័យរាស្ត្រជាធំ ។
ប្រជានុរាស្ត្រជាកម្លាំង    ក្នុងរដ្ឋក្លាខ្លាំងយ៉ាងរឹងមាំ
ជនណាធ្វើមេត្រូវនិយម    យករាស្ត្រឧត្តមជាប្រមុខ ។
មេនោះមានឈ្មោះជាមេពិត    មានចិត្តស្នេហ៍ស្និទ្ធដឹងសុខទុក្ខ
ដឹងខុសដឹងត្រូវហ៊ានចេញមុខ    ទទួលបន្ទុកគ្រប់កិច្ចការ ។
បើមេតាំងចិត្តគិតគោងកាច    ប្រព្រឹត្តមិនខ្លាចខុសតម្រា
មានចិត្តឃោឃៅចាប់ទោសា    ចោទដល់អ្នកណាប្រឆាំងខ្លួន ។
ទង្វើដូច្នេះបញ្ជាក់ថា    ជាជនផ្តាច់ការល្មមគ្រប់ធ្ងន់
ចាត់ទុកជាជនមិនសមសួន    ជាមេនាំកូនបានទៀតទេ ។
អំពើផ្តាច់ការត្រូវកំចាត់    ចេញទៅឱ្យបាត់ពីជាតិខ្មែរ
យកមេនាំល្អចេះពូកែ    នាំជាតិឱ្យស្នេហ៍ប្រជាធិបតេយ្យពិតអើយ ៕


# Washington Wellness Care

●បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត, មានរបួសនៅកន្លែងធ្វើការ ឬក៏រអិលហើយដួលរហូតដល់មានរបួសតែពុំដឹងនរណាជា អ្នកទទួលខុសត្រូវ ?






**●យើងអាចជួយលោកអ្នកបាន**

●មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្តាលឱ្យរបួស

●យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់

●អាចផ្តល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង

●សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា

**វីតី និយាយភាសាខ្មែរ លេខទូរស័ព្ទ : 267-982-1977**

500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838

The Cambodia Daily

Saturday- Sunday August 1-2-2009 ដើម្បីស្វាគមន៍ដល់លោកអ្នកអានថ្មីៗទៀត... ខ្មែរប៉ុស្តិ៍បានសម្រេចដកស្រង់ព័ត៌មានជាភាសាអង់គ្លេស ដែលនាយកសារព័ត៌មាន The Cambodia Daily បានអនុញ្ញាតិឱ្យយើងចុះផ្សាយ ដើម្បីជាព័ត៌មានពីកម្ពុជាដល់សាធារណជន ដែលមិនអាចអានព័ត៌មានជាភាសាខ្មែរបាន ។

# Dam Project a Dilemma for Stung Treng Villagers

By Neov Vannrin
and Paul Vrieze
The Cambodai Daily



Neov Vannarin/The Cambodai Daily

Night fall over the Sesan River in Stung Treng province's Phluk village, where plan have been drown up for a massive hyropower dam that will require the resettlement of move than 1,000 families and the flowing of move than 30,000 hectares of forest and farmland.

SESAN DISTRICT, Stung Treng province - The site of the planned Lower Sesan 2 Dam is largely untouched by development. Move than 1000-meters wide, the Sesan River runs quietly along the bamboo and jungle covered river backs here.

But this could all change, and possibly within months when work on the 75-meter high, $816 million Sesan dam begins. The multi-million dollar hydropower project requires the resettlement of move than 1,000 families from seven villages upstream of the dam and the clearing of the contruction area, conpany officails from Electricite du Vietnam, the developer of the 400-megawatt hydropower project, said Thursday.

If the project goes ahead, the dam,which will be located on the Sesan River about 25 km from Trung Treng town and a kilometer downstream from where the Sesan and Srepok river converge, will raise water levels and inundate approximately 30,000 hectares of land along the two rivers which is mostly forested land except for around 12,000 hetares of farmland, according to an enviroment impact of the project.

An official with EVN, who asked not to be named, said be telephone from Vietnam that Cambodai's Finance Ministry and the gavernment's Inter-ministerial Resettlement Committee had exccepted a resettlement action plan drafted be Power Engineering Consuting Company 1, the project's engineering consultant, and that EVN was now waiting approval from the government to begin the project.

"We have submitted all documents on resettlement to the government and they issued a letter that agreed with the content of our resettlement action plan. We are now waiting for final government approval," the EVN official said.

"I hope they agree soon, I expect a decision within two months," the official said adding, "whenever the approval comes work will start immediately."

"All preparations are finished and we can start with resettlement and site vacantion." he added.

However Chhorn Sopheap, director of the government's resettlement committee, said on Friday that he had not yet seen any approval documents and the government and EVN are still in discussion about the resettlement operation.

"There will remain a very longtime before resettlement [starts]," Mr Sopheap said, adding that EVN and the government "are now interacting with each other," as project documents needed to be adapted.

Nevertheless, Taing Sophanara from Key Consutants Cambodai, the agency selected be PECC 1 to prepare the enviromental impact assessment for the lower Sesan 2 dam, said he had also been in formed that the government had approved PECC 1's resettlement plan.

In March, hundreds of Vietnamese workers from EVN were seen drilling for geological samples at the proposed dam site in Phluk commune. The project will require around 3,000 workers who will live at the site for around four years to build the dam. The electricity generated by the hydropower installation will go to Stung Treng, Ratanakkiri and Kratie province, while remaining power will be exported to Vietnam, according to the EIA report.

A study by the Rivers Coalition of Cambodai, which was publicly unveiled in Ratanakkiri provice by NGO Forum on Wednesday, found that none of the residents in seven villages in Srekor, Talat and Kbal Romea communes and four other villages both up- and downriver agreed with the project due to the impact on their lives.

Civil society groups are "seriously concenrned" about the livelihoods of the affected communities and public consultations are required to make sure the people affected be the dam are projected, said Chhith Sam Ath, executive director of NGO Forum.

NGO Forum had repeatedly asked the government for information on the project, but these requestes had gone unanswered and only in the June had they been given sccess to a draft EIA, he said .

More and broader public cousutation is needed, Mr Sam Ath said, as the local consultancy KCC has interviewed people only in the planned dam resorvoir area within talking to any of the tens of thousands of villages living futher up- and downstream of the dam.

These communities, he said would be affected be the loss of fishing opportunities, reduced water quality, which could lead to water-borne diseases, and the impact of an influx of migrant workers into the area, NGO Forum said.

NGO Forum also pointed to a pre-feasibility study condusted by the Asia Development Back in 1990 that four the Lower Sesan 2 Dam to be unattrative for investment due to its maginal financial viability and the extremety heavy environmental and sicial impact of the dam.

According to Mr Sam Ath, the proposed relocation site for the villagers, who mostly rely on fishing, in far from the river, is characterized by poor quality agricultural land and is partially located in areas of economic land concessions and important wildlife habitats. Companstion for their loss of agricultural land, houses and orchards proposed in the EIA is inadequate and no regulatory framework is in place to guarantee the compensation rights of displaced villagers, he added.

Mr Sam Ath called on the government to have the EIA redone according to the standards of "international best practices for dam development."

" The NGO community is happy to cooperate with the government and work on the resettlement plans, but without information we cannot do anything," he said.

( Continued on page 13 )

ART OF WELLNESS CENTER



"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



មន្ទីរសុខភាព "Art of Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចិមប្រទេស ។

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

ទទួលព្យាបាលបានគ្រប់វ័យ

| របៀបព្យាបាល | TREATMENT TYPE |
|---|---|
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

វេជ្ជបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។

សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238

ភាសាខ្មែរទាក់ទង ប៊ុន ភឹក : 267-242-8526

(តមកពីទំព័រទី ០១)

# កុំភ័យខ្លាចការធ្វើជំរឿនស្ថិតិ...

(Immigration Department) ផងដែរ ។

ពួកមន្ត្រីជំរឿននិយាយថា ការធ្វើជំរឿនស្រង់ចំនួនស្ថិតិប្រជាជនដែលធ្វើឡើងរយៈពេល 10ឆ្នាំ ម្តងនោះ គឺផ្តល់នូវសារប្រយោជន៍សំរាប់ធ្វើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងការរស់នៅរបស់ពលរដ្ឋឱ្យមាននិរន្តភាព ដូចជាអាចជួយឱ្យមានសេចក្តីសម្រេចក្នុងការកំណត់ទីតាំងដើម្បីស្ថាបនាសាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ មន្ទីរថែរក្សា កូនក្មេង និងមជ្ឈមណ្ឌលមនុស្សចាស់ជរា ។ល។

រីឯវិស័យពាណិជ្ជកម្មក៏ត្រូវបានប្រើប្រាស់ទិន្នន័យពីការធ្វើជំរឿនប្រជាជននេះដែរ ក្នុងការពង្រីកឥទ្ធិពលទីផ្សារក្នុងប្រព័ន្ធសេដ្ឋកិច្ចបែបសាកលភាវូបនីយកម្មតំបន់ និងពិភពលោក ការសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម និងអគារផ្សេងៗទៀតបន្ថែមដើម្បីតម្រូវការរស់នៅនៃអត្រាការកំណើនរបស់មនុស្ស ។

ការជំរឿននោះទៀតសោតក៏នឹងជួយធ្វើឱ្យមានការសម្រេចក្នុងការបែងចែកចំនួនអាសនៈនៃតំណាងរាស្ត្រប្រចាំរដ្ឋនីមួយៗនៅក្នុងសភាសហរដ្ឋអាមេរិករួមទាំងការកំណត់នូវព្រំដែនតំបន់នៃផ្នែកនីតិបញ្ញត្តិផងដែរ ។



មន្ត្រីជំរឿនកំពុងពន្យល់បងប្អូនខ្មែរឱ្យយល់ដឹងពីការធ្វើជំរឿនស្ថិតិប្រជាជន (រូបថតខ្មែរប៉ុស្ដិ៍)



ចៅហ្វាយក្រុង Bob Foster និងចៅសង្កាត់ Dee Andrews (រូបថតខ្មែរប៉ុស្ដិ៍)

